# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីសម្រេចបន្តអាណត្តិអាជ្ញាប័ណ្ណរូបលេខ ០៣៩ ឯអ
## សំរាប់លោក គីម ច័ន្ទតារា
# អាជ្ញាធរអគ្គិសនីកម្ពុជា

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ។

-យោងឯកសារអាជ្ញាប័ណ្ណលេខ ០៣៩ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាបានចេញឱ្យលោក គីម ច័ន្ទតារា នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៣

-យោងពាក្យស្នើសុំបន្តអាណត្តិអាជ្ញាប័ណ្ណ របស់លោក គីម ច័ន្ទតារា ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៥

-យោងកំណត់បង្ហាញសុំបន្តអាណត្តិអាជ្ញាប័ណ្ណរបស់លេខាធិការដ្ឋានលេខ ០១៩-០៥-លជ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០០៥

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៥ ដល់ថ្ងៃ ទី១៣ ខែមិថុនា ឆ្នាំ២០០៥

-យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី៥៣ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៥

## សម្រេច

**ប្រការ១**

ដោយលោក **គីម ច័ន្ទតារា** បានកែលំអមធ្យោបាយធ្វើសេវាកម្មអគ្គិសនី របស់ខ្លួនបានតិចតួច ហើយត្រូវធ្វើការកែលំអច្រើនបន្ថែមទៀតនៅឆ្នាំបន្តបន្ទាប់ ដើម្បីឱ្យស្របតាមល័ក្ខខ័ណ្ឌទូទៅនៃស្តង់ដាបច្ចេកទេសអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចកែសម្រួលអាជ្ញាប័ណ្ណរូបលេខ ០៣៩ ឯអ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៣ ដែលបានផ្តល់ជូនលោក **គីម ច័ន្ទតារា** ដោយបន្តអាណត្តិអាជ្ញាប័ណ្ណសាកល្បងចុងក្រោយចំនួន ២ឆ្នាំ ទៀត ។

**ប្រការ២**

អាណត្តិសាកល្បងចុងក្រោយនៃអាជ្ញាប័ណ្ណនេះ មានរយៈពេល ២ឆ្នាំ គិត ចាប់ពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៥ និងអាចស្នើសុំបន្តទៀត ឬស្នើសុំកែសម្រួល លើកលែងតែត្រូវដកហូតដោយអនុលោមតាមល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ។

**ប្រការ៣**

សេចក្តីសម្រេចនេះ ត្រូវក្លាយជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ០៣៩ ឯអ ។

**ប្រការ៤**

ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ០៣៩ ឯអ ត្រូវ ស្ថិតនៅជាធរមានដដែល ។

**ប្រការ៥**

សេចក្តីសម្រេចនេះ ត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៦**

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះទៅតម្កល់ទុកបន្ថែមនៅតាម ទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ០៣៩ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯក សារអាជ្ញាប័ណ្ណលេខ ០៣៩ឯអ ដែលតម្កល់មានការកែសម្រួលជាថ្មី ស្របតាម សេចក្តីសម្រេចនេះ ។

ភ្នំពេញ, ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៥

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

## ឧបសម្ព័ន្ធទី២
## មធ្យោបាយផលិតកម្មដែលមានស្រាប់របស់អ្នកកាន់អាជ្ញាប័ណ្ណ

### ក_មធ្យោបាយផលិតកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណ

### រោងម៉ាស៊ីន

១- រោងម៉ាស៊ីនរបស់អ្នកកាន់អាជ្ញាប័ណ្ណ គឺរោងសាងសង់ដោយជញ្ជាំងឈើ ដំបូលប្រក់ស័ង្កសី ទំហំ ៨ x ៨ ម៉ែត្រ ស្ថិតក្នុងភូមិថ្នល់ជាតិ ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

### លក្ខណៈទូទៅនៃម៉ាស៊ីន

១- អ្នកកាន់អាជ្ញាប័ណ្ណ មានម៉ាស៊ីនភ្លើងចំនួន ០២គ្រឿង ដែលមានអានុភាព តំឡើងសរុប 70kVA គឺ:

-ម៉ាស៊ីនទី១ : អានុភាពដើម 50kVA

-ម៉ាស៊ីនទី២ : អានុភាពដើម 20kVA

២- ម៉ាស៊ីនភ្លើងខាងលើ ប្រើប្រាស់ប្រេងដ្យេសែល ។

លក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណនេះមានខ្លឹមសារដូចអាជ្ញាប័ណ្ណលេខ០១៥.ឯអ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០២។ ប្រសិនបើចង់ពិនិត្យមើលខ្លឹមសារ សូមពិនិត្យមើលផ្នែកទី២ របស់អាជ្ញាប័ណ្ណនេះ ។